មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# វិចារណកថាព័ត៌មានរបស់ ម.ស.ម.ក

ភ្នំពេញ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១២

## ការវាយប្រហារដោយអាស៊ីដថ្មីៗនេះ បង្ហាញពីភាពអសកម្មនៃការអនុវត្តន៍ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង

យោងតាមអត្ថបទកាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១២ នៅលើសារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍ (ចំណងជើង "ការស្លាប់ដោយសារការវាយប្រហារដោយអាស៊ីដអាចជាការសាកល្បងច្បាប់") ស្ត្រីម្នាក់ត្រូវបានស្លាប់បន្ទាប់ពីក្លាយជាជនរងគ្រោះនៃការវាយប្រហារដោយទឹកអាស៊ីដយ៉ាងឃោរឃៅមួយក្នុងខេត្តព្រះសីហនុ។ ជនរងគ្រោះ កញ្ញា គ្រុយ អៀងឆេង មានអាយុ២០ឆ្នាំ ហើយធ្វើការជាបុគ្គលិកចែកសន្លឹកបៀរនៅកាស៊ីណូក្នុងខេត្តព្រះសីហនុ។ នាងត្រូវបានវាយប្រហារក្នុងយប់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២ ដែលពេលនោះទឹកអាស៊ីដត្រូវបានស្រោចលើក្បាល និងចាក់ចូលទៅក្នុងមាត់របស់នាង។ នាងបានស្លាប់ដោយសារតែរបួសរបស់នាង បន្ទាប់ពីត្រូវបាននាំយកមកកាន់មន្ទីរពេទ្យរាជធានីភ្នំពេញ។ មិត្តប្រុសរបស់នាងជាបុគ្គលម្នាក់ដែលអាជ្ញាធរត្រូវការសម្រាប់សាកសួរបានរត់គេចខ្លួនចាប់តាំងពីពេលនោះមក។

យោងតាមទិន្នន័យដែលបានប្រមូលដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ការវាយប្រហារនេះជាការវាយប្រហារលើកទី៦ ក្នុងឆ្នាំ២០១២ និងជាករណីទីពីរដែលជនរងគ្រោះត្រូវទទួលមរណភាពដោយសារតែរបួសរបស់ពួកគេ។ ករណីមួយទៀតដែលកើតឡើងក្នុងខេត្តកំពង់ចាមក៏បានបណ្តាលឲ្យជនរងគ្រោះម្នាក់ត្រូវស្លាប់ និងជនរងគ្រោះម្នាក់ទៀតត្រូវរងរបួសយ៉ាងទម្ងន់។ គ្មានករណីណាមួយក្នុងចំណោមករណីទាំង៦ ដែលបានលើកឡើងដោយ ម.ស.ម.ក ត្រូវបាននាំយកមកកាន់តុលាការនៅឡើយទេ ទោះបីជាមានច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង ("ច្បាប់គ្រប់គ្រងអាស៊ីដ") ដែលត្រូវបានអនុម័តកាលពីដើមខែធ្នូ ឆ្នាំ២០១១ក៏ដោយ។ ករណីថ្មីៗនេះបង្ហាញថារយៈពេលមួយឆ្នាំក្រោយមក នៅតែមានការវិវឌ្ឍន៍ច្រើនទៀតដែលធ្វើក្នុងការអនុវត្តន៍ច្បាប់នេះ ហើយដើម្បីធានាថាករណីវាយប្រហារដោយអាស៊ីដត្រូវបានបញ្ឈប់នៅកម្ពុជា។

**ឆ្លើយតបទៅនឹងការវាយប្រហារក្នុងពេលថ្មីៗនេះ កញ្ញា សន រ៉ាមណា ដែលជាមន្ត្រីសម្របសម្រួលគម្រោង នៃ ម.ស.ម.ក បានមានប្រសាសន៍ថា ៖**

*"អាជ្ញាធរគ្រប់ជាន់ថ្នាក់គួរតែធានាថាជនល្មើសនៃករណីវាយប្រហារដោយអាស៊ីដនេះត្រូវបានចាប់ខ្លួន និងនាំយកមកតុលាការដើម្បីផ្តន្ទាទោស។ បន្ថែមពីលើនោះ រដ្ឋាភិបាលគួរតែចាត់វិធានការបន្ថែមដើម្បីធានាថាច្បាប់គ្រប់គ្រងអាស៊ីដ ដែលបានអនុម័តរយៈពេលមួយឆ្នាំបើគិតមកដល់ខែនេះ ដើម្បីធានាថាច្បាប់នេះត្រូវបានប្រើប្រាស់ដើម្បីផ្តន្ទាទោសជនល្មើសនៃករណីវាយប្រហារដោយអាស៊ីដ។ ខណៈពេលដែលយើងទទួលបាននូវការលើកទឹកចិត្តដែលរដ្ឋាភិបាល បានឈានមួយជំហានក្នុងការអនុម័តច្បាប់គ្រប់គ្រងអាស៊ីដ យើងមានការព្រួយបារម្ភថាច្បាប់គ្រប់គ្រងអាស៊ីដមិនត្រូវបានអនុវត្តនៅឡើយ។ បន្ថែមពី*

*លើនោះ ច្បាប់គ្រប់គ្រងអាស៊ីដគួរតែត្រូវបានបំពេញបន្ថែមដោយអនុក្រឹត្យដើម្បីបញ្ជាក់ឲ្យបានច្បាស់ពីបញ្ញត្តក្នុងច្បាប់គ្រប់គ្រងអាស៊ីដ ដើម្បីអាចធានាបានថាជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេទទួលបានជំនួយផ្នែកវេជ្ជសាស្ត្រ និងផ្នែកច្បាប់"* ។

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង កញ្ញា សន រ៉ាមណា តាមរយៈទូរសព្ទ +៨៥៥ (០) ១៧ ៥៥ ៦៥ ៩១ ឬអ៊ីម៉ែល ramanasorn@cchrcambodia.org ឬទីប្រឹក្សារបស់ ម.ស.ម.ក កញ្ញា ជូលីយែត រូសេលត តាមរយៈទូរសព្ទ +៨៥៥ (០) ១៥ ៣៥ ០៦ ២០ ឬអ៊ីម៉ែល juliettrousselot@cchrcambodia.org ។**

<u>បណ្ណាធិការ</u>

ម.ស.ម.ក ត្រូវបានបង្កើតឡើងនៅក្នុង ខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅកម្ពុជា។

ម.ស.ម.ក គឺជាសមាជិករបស់ ដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អ៊ីហ្វិក) ដែលជាបណ្តាញសកលដើម្បីការបញ្ចេញមតិដោយសេរី។

គេហទំព័រស្តីពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានរង្វាន់ប្រចាំឆ្នាំ២០១១របស់មូលនិធិនៃការបង្កើតថ្មីសម្រាប់សង្គមព័ត៌មានវិទ្យា ក្នុងចំណាត់ថ្នាក់នៃ សិទ្ធិ និងសេរីភាព។